**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៧៨)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៥ ៥៧៦នាក់ នៃរោងចក្រ សហគ្រាសទាំង៤២ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ៧៥០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាសទាំង៤២ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ សុក្រ ៣កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ២០២២

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤ ៣៧៥ និងទូរសារ :(០២៣)៨៨៤ ២៧ ៦៩

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២**

**បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍**
**ចំនួន ៤២ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 9 |
| 1 | ក្រុមហ៊ុន អេខ្ញើអេកស្ព៍ឌីសិន (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 2 | ក្រុមហ៊ុន សិន តៃ ហ្គាមេន(ខេមបូឌា)ខូអិលធីឌី | ភ្នំពេញ |
| 3 | ក្រុមហ៊ុន គ្លូរី នីត វែរ អិលធីឌី | កណ្តាល |
| 4 | ក្រុមហ៊ុនវ៉ាន់ ស៊ីង នីតធីង អ៊ិនធើណេសិនណល ឯក | កណ្តាល |
| 5 | ក្រុមហ៊ុន ស៊ីអិនឌីហ្វ្រី អិនធើណេសិនណល (ខេអេច) ឯ.ក | កំពង់ស្ពឺ |
| 6 | ក្រុមហ៊ុនអ៊ែដ្យាយល៍ ស្វេតចី(ខេមបូឌា)ខូ អិលធីឌី | កំពង់ស្ពឺ |
| 7 | ក្រុមហ៊ុន លីឌីង ស្តារ (ខេមបូឌា)ហ្គាម៉ិន ឯ.ក | តាកែវ |
| 8 | ក្រុមហ៊ុន ប្រេ្តសហ្វូល(ខេបូឌា)ថេកស្ថាយ ខូ.អិលធីឌី | តាកែវ |
| 9 | ក្រុមហ៊ុន យ៉កស៍(ខេមបូឌា) ខូអិលធីឌី | ស្វាយរៀង |
| ខ. វិស័យទេសចរណ៍ | | 33 |
| 10 | ក្រុមហ៊ុន ហ៊្វូដឡាយហ្វ៍ ឯ.ក | ភ្នំពេញ |
| 11 | ក្រុមហ៊ុន ដារ៉ា អ៊ែរផត ហូថេល | ភ្នំពេញ |
| 12 | សណ្ឋាគារ រ៉េស៊ីដង់ សុខាភ្នំពេញ | ភ្នំពេញ |
| 13 | សណ្ឋាគារ អូឡាំព្យា ស៊ីធី ហូថេល | ភ្នំពេញ |
| 14 | ក្រុមហ៊ុន រ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |
| 15 | សណ្ឋាគារ លីនាយាអង្គរ រីសត និងស្ប៉ា | សៀមរាប |
| 16 | សណ្ឋាគារគូលែន | សៀមរាប |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 17 | អាហារដ្ឋានផ្ទះបាយខ្មែរភឿក | សៀមរាប |
| 18 | សណ្ឋាគារវិក្តូរីយ៉ាអង្គរ រីសត និង ស្ប៉ា | សៀមរាប |
| 19 | សណ្ឋាគារម៉េម័រសៀមរាប | សៀមរាប |
| 20 | ក្រុមហ៊ុន សិប្បករអង្គរ | សៀមរាប |
| 21 | ក្រុមហ៊ុន ដំរីអង្គរ ខូ អិលធីឌី | សៀមរាប |
| 22 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា (ភោជនីយដ្ឋានទន្លមេគង្គ) | សៀមរាប |
| 23 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា (ភោជនីយដ្ឋានទន្លេសាប) | សៀមរាប |
| 24 | ក្រុមហ៊ុន កូបេ យៃគែននីស រ៉ែស្តូរ៉ង់ | សៀមរាប |
| 25 | សណ្ឋាគារដឺឡាពេ (ផាកហៃយ៉ាត់សៀមរាប) | សៀមរាប |
| 26 | សណ្ឋាគារសុខាល័យអង្គរ រីហ្សត និងស្ប៉ា | សៀមរាប |
| 27 | សណ្ឋាគារ អង្គរ | សៀមរាប |
| 28 | សណ្ឋាគារប៉ាស៊ីហ្វិក | សៀមរាប |
| 29 | ក្រុមហ៊ុន អង្គរ សេនជូរី គ្រុប ភីធីអ៊ី អែលធីឌី | សៀមរាប |
| 30 | ក្រុមហ៊ុន ផ្កាចន្ទន៍ សៀមរាប យ៉ុងឆាង | សៀមរាប |
| 31 | សណ្ឋាគារ រីចេនស៊ីអង្គរ | សៀមរាប |
| 32 | ក្រុមហ៊ុន វីត្រូ អ៊ិនវេសមេន | សៀមរាប |
| 33 | សណ្ឋាគារ អង្គរប៉ារ៉ាឌី | សៀមរាប |
| 34 | សណ្ឋាគារ វិរតន៍ | សៀមរាប |
| 35 | ក្រុមហ៊ុនវិរតន៍ វីឡា | សៀមរាប |
| 36 | សណ្ឋាគារ ស្វាយលីង | សៀមរាប |
| 37 | សណ្ឋាគារសុខាសៀមរាប | សៀមរាប |
| 38 | សណ្ឋាគារ សុខាអង្គរ | សៀមរាប |
| 39 | សណ្ឋាគារ អូរៀនថល ជេ7 | សៀមរាប |
| 40 | ក្រុមហ៊ុន ហ្វូខឹស អេស៊ា អ៊ីនធើណេសិនណលត្រាវែល ស៊ីវីស | សៀមរាប |
| 41 | ក្រុមហ៊ុន អង្គរ ហូលីដេ | សៀមរាប |
| 42 | ក្រុមហ៊ុន អង្គរកែលេសរីហ្សត និងស្ប៉ា | សៀមរាប |